ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៣១៦៩ ព.ណ ន.នច

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## ការដាក់ឱ្យប្រើប្រាស់ វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់អេឡិចត្រូនិក (e-Certificate of Origin)

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនផលិតករ និងអ្នកនាំចេញទាំងអស់ឱ្យបានជ្រាបថា ដើម្បីបន្តចូលរួមលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម ពិសេសការធ្វើទំនើបកម្មការផ្តល់សេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិកដែលធានាបាននូវតម្លាភាព ទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញ និងអនុលោមតាមលក្ខខណ្ឌតម្រូវនៃវិធានដើមកំណើតទំនិញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្រសួងបានដាក់ឱ្យប្រើប្រាស់ ការចេញ វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញជាទម្រង់អេឡិចត្រូនិក (e-Certificate of Origin) តាមរយៈគេហទំព័រ **co.moc.gov.kh** ដែលត្រូវអនុវត្តរួមជាមួយប្រកាសចំនួន ៥ ដូចមានចែងនៅក្នុងច្បាប់ ស្តីពីវិធានដើមកំណើតទំនិញ ដូចខាងក្រោម៖

- ប្រកាស ស្តីពីនីតិវិធីក្នុងការស្នើសុំ និងផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ
- ប្រកាស ស្តីពីទម្រង់ និងព័ត៌មានអប្បបរមា នៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃទំនិញនាំចេញ
- ប្រកាស ស្តីពីនីតិវិធីក្នុងការកំណត់យថាភូតភាព នៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់អេឡិចត្រូនិក
- ប្រកាស ស្តីពីនីតិវិធីនៃការស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ
- ប្រកាស ស្តីពីបែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល ចំពោះបទល្មើសពាក់ព័ន្ធនឹងដើមកំណើតទំនិញ

ជាមួយគ្នានេះ ក្រសួងក៏បាន ១. ដាក់ឱ្យប្រើប្រាស់ថ្នាលព័ត៌មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា (Cambodia FTA Portal) កាលពីខែធ្នូ ឆ្នាំ២០២៥ ដែលមានមុខងារប្រៀបធៀបអត្រាពន្ធគយ វិធានដើមកំណើតទំនិញ និងឯកសារតម្រូវផ្សេងទៀតសម្រាប់គាំទ្រដល់ផលិតករ និងអ្នកនាំចេញក្នុងការជ្រើសរើសកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីណាមួយដែលផ្តល់អត្ថប្រយោជន៍បំផុត សម្រាប់នាំចេញទំនិញទៅទីផ្សារគោលដៅតាមរយៈគេហទំព័រ **ftaportal.moc.gov.kh** និង ២. បានបកប្រែច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ជាភាសាអង់គ្លេស ចិន ជប៉ុន និងកូរ៉េ និងប្រកាសទាំង ៥ ខាងលើជាភាសាអង់គ្លេស ជូនដល់ផលិតករ និងអ្នកនាំចេញជាតិនិងអន្តរជាតិដែលកំពុងធ្វើធុរកិច្ចនៅកម្ពុជា ឲ្យកាន់តែជ្រួតជ្រាបបន្ថែមនូវច្បាប់ បែបបទ និងនីតិវិធីដែលមានជាធរមាន ដូចមានជូនភ្ជាប់ក្នុង ឃ្យូ.អ.កូដ (QR Code)។

អាស្រ័យហេតុនេះ សូម ផលិតករ និងអ្នកនាំចេញទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យបានគត់មត់។

ថ្ងៃអង្គារ ៤រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ[illegible] ឆ្នាំ២០២៦

**ស្កេនដើម្បីទាញយកឯកសារខាងលើ**

**ស្កេនដើម្បីចូលតំណភ្ជាប់**

**ប្រព័ន្ធទូរសព្ទសាធារណៈ ក្រសួងពាណិជ្ជកម្ម**

1266